**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០៧...សសរ

# <u>សេចក្ដីសំរេច</u>

## ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ក្នុងការរៀបចំឯកសារបទដ្ឋានគតិយុត្តិ និងប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទកោះកេរ្តិ៍ និងបឹងមាលា សំរាប់បំរើសំណូមពរវិនិយោគ របស់ ក្រុមហ៊ុន KHAM SOMETH CO., LTD

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣ /នស /៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ ក.អ .ក"គ.វ.ក" នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០០១
- តាមសំណើរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# សំរេច

**ប្រការ១:** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំរាល់ឯកសារបទដ្ឋានគតិយុត្តិ និងប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទកោះកេរ្តិ៍ និងបឹងមាលា សំរាប់បំរើសំណូមពរវិនិយោគរបស់ក្រុមហ៊ុន KHAM SOMETH CO., LTD. ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ឆី យ៉ាំទ | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | ឯកឧត្តម គង់ វិបុល | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម ជុច ភឿន | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- | ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥- | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- | ឯកឧត្តម រស់ រ៉េន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- | ឯកឧត្តម រ័ត្ន សណ្ណាប់ | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម អ៊ុត ឈូអ៊ី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | ឯកឧត្តម អ៊ុក ចាន់ | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- | ឯកឧត្តម សេង លឹមនៅ | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១- | ឯកឧត្តម ដោក ណារិន | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ១២- | ឯកឧត្តម ត្រាប តាន់ | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ១៣- | ឯកឧត្តម រស់ បូរ៉ាត់ | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៤- | លោក ស៊ុយ សាន | អភិបាលរងទី២ ខេត្តសៀមរាប | សមាជិក |
| ១៥- | លោក មុខ ម៉ិនហួន | ប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** គណៈកម្មការដូចមានចែងក្នុងប្រការ១ខាងលើ មានភារកិច្ចដូចខាងក្រោម :

- រៀបចំបែបបទ ឯកសារគតិយុត្តិ-កំណត់ផែនការសកម្មភាព ព្រមទាំងរៀបចំប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិវប្បធម៌ទាំង២កន្លែង "តំបន់ប្រាសាទកោះកេរ្តិ៍-តំបន់ប្រាសាទបឹងមាលា" អោយបានច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងថែរក្សាតំបន់ប្រាសាទអោយបានល្អតាមលំនាំនៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យកន្លងមក
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តការងាររបស់ក្រុមហ៊ុន តាមជំហាននីមួយៗ
- លើកសំណើ សុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន
- រាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣** : គណៈកម្មការនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេច នេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *កាលប្បវត្តិ-ឯកសារ*

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន